# ឯកសារជំនួយស្មារតី
# របស់លោក លី ហ៊ត ប្រធានក្រុមប្រឹក្សាឃុំពងទឹក
## ក្នុងសន្និសីទសារព័ត៌មាន ស្តីពីវឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត
នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១

**ជាបឋម ខ្ញុំព្រះករុណា-ខ្ញុំបាទ៖**

- សូមក្រាបថ្វាយបង្គំសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ !
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !
- សូមគោរព ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរព!
- សូមគោរព ឯកឧត្តម **សំ សារីន** ប្រធានក្រុមប្រឹក្សាខេត្ត និងគណៈប្រតិភូខេត្តកែប ជាទីគោរព!
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មាន ដែលមានវត្តមាននៅក្នុងឱកាសនេះ ជាទីគោរព!

ថ្ងៃនេះ ក្នុងនាមក្រុមប្រឹក្សាឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ ដែលត្រូវបានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល អញ្ជើញឱ្យចូលរួមជាវាគ្មិនកិត្តិយសដើម្បីធ្វើបទបង្ហាញស្តីពីវឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តនាពេលនេះ។

អនុញ្ញាតឱ្យខ្ញុំព្រះករុណា-ខ្ញុំបាទ សូមគោរពរាយការណ៍ជូនសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អំពីស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពល សមិទ្ធផលនៃការអភិវឌ្ឍន៍ ស្ថានភាពសេដ្ឋកិច្ចរបស់ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ដូចតទៅ៖

### ១.សេចក្តីផ្តើម

ឃុំពងទឹក គឺជាឃុំមួយក្នុងចំណោមឃុំទាំងពីរនៅក្នុងស្រុកដំណាក់ចង្អើរ ខេត្តកែប ដែលមានព្រំប្រទល់ -ខាងលិចទល់និងឃុំត្រពាំងព្រីង ស្រុកទឹកឈូ ខេត្តកំពត និងសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប -ខាងកើតទល់និងឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត-ខាងជើងទល់និងជួរភ្នំវល្លិ៍ ឃុំស្រែជាខាងត្បូង ស្រុកដង់ទង់ ខេត្តកំពត-ខាងត្បូងទល់និងឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប មាន០៧ ភូមិ គ្រួសារសរុប ២៩៦៦ គ្រួសារ ប្រជាពលរដ្ឋសរុប ១២.០១៨នាក់ ស្រី ៦០៤៦ នាក់ ប្រជាពលរដ្ឋ១៨ឆ្នាំមាន ៧.២៦៥នាក់ ស្រី ៣.៨៤៧នាក់ ប្រជាពលរដ្ឋក្រោមអាយុ១៨ឆ្នាំ ៤.៧៥៣នាក់ ប្រជាពលរដ្ឋសំណាក់ស្រុក ៦៤៣នាក់ ស្រី ៣៣៦នាក់។ ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ៦.៥៦២នាក់ ស្រី៣.៣១៩នាក់។

សក្តានុពលសេដ្ឋកិច្ចរបស់ឃុំ មានផ្ទៃដី ១២.៩០០ហិកា ពឹងផ្អែកលើវិស័យកសិកម្ម ដូចជា ធ្វើស្រែ និងចំការរួមមានម្រេច ធុរេន ស្វាយ ពោត អំពៅ ដំឡូងជ្វា និងនេសាទ។

### ២.អំពីវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាឃុំ

-មានផ្សារមានចំនួន ០២កន្លែង

-មតេយ្យសហគមន៍ ០២កន្លែង សាលាភាសាចិន ០១កន្លែង សាលាបឋមសិក្សាមានចំនួន ០៧កន្លែង អនុវិទ្យាល័យ ០២កន្លែង និងវិទ្យាល័យ ០១កន្លែង។

-មានមណ្ឌលសុខភាពចំនួន ០២កន្លែង។

-វត្តអារាមព្រះពុទ្ធសាសនាមាន ៥កន្លែង។

-ឃុំបានបំរើសេវាសាធារណៈជូនប្រជាពលរដ្ឋដោយអនុវត្តគម្រោងច្រកចេញ-ចូលតែមួយអត្តសញ្ញាណកម្ម ប្រើប្រព័ន្ធបច្ចេកវិទ្យាអនឡាញ សម្រាប់បញ្ចូលទិន្នន័យ ដែលជាហេតុធ្វើឱ្យការងារផ្តល់សេវាមានភាពលឿនរហ័សទាន់ចិត្ត។

-បានចូលរួមដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាជូនប្រជាពលរដ្ឋ

-ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពទទួលបានជ័យលាភីលេខ១ លេខ២

-បានចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋបានចំនួន ០៦ភូមិ លើ ៧ភូមិ។

-ក្នុងឃុំពងទឹក មានសិប្បកម្មចំនួន ០៤ កន្លែង។

-ប្រជាជនដែលមានបណ្តាញអគ្គិសនីប្រើប្រាស់ ៧ភូមិ និងមានប្រព័ន្ធទឹកស្អាតប្រើប្រាស់ចំនួន ៧ភូមិ មិនទាន់គ្រប់ខ្នងផ្ទះនៅឡើយ។

-មានទំនប់ ០៩កន្លែង ប្រឡាយទឹកមេ ១២ខ្សែ និងប្រឡាយរង៨ខ្សែ ស្រះទឹកមានចំនួន ១១៧ស្រះ និងអណ្តូងទឹកមានចំនួន ៦៩អណ្តូង ។

-មានផ្លូវក្រាលកៅស៊ូចំនួន០៤ខ្សែ ដែលមានប្រវែងសរុប ៧,៦១២ម៉ែត្រ ផ្លូវបេតុងចំនួន ០១ខ្សែ ប្រវែង ៩៨០ម៉ែត្រ និងផ្លូវលំក្រាលក្រួសក្រហម ២៦ខ្សែ មានប្រវែងសរុប ៦៥,១៣០ ម៉ែត្រ។

-អត្រាក្រីក្រនៅក្នុងឃុំពងទឹកនៅសល់ ២,៧% (ឆ្នាំ២០១៩) មានគ្រួសារក្រីក្រសរុប៣៤៣ ក្នុងនោះក្រីក្រក្នុងអំឡុង កូវីដ ១៩ មាន ៤២គ្រួសារ (មានក្រ១ =១១០គ្រួសារ និងក្រ២=២៣៤គ្រួសារ) ។

-ក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរជំនាញបានផ្សព្វផ្សាយ និងជំរុញដល់ប្រជាពលរដ្ឋ បង្កើនការដាំដុះ បន្លែ ផ្លែឈើ ការចិញ្ចឹមសត្វ ចញ្ចឹមត្រី កង្កែប ក្នុងនោះក៏មានគម្រោង អាស់ស្បាយ ចងក្រងជាបណ្តុំដាំបន្លែគ្រប់មុខ ដាំស្វាយ ដាំពោត ចិញ្ចឹមមាន់ ចិញ្ចឹមត្រី ចិញ្ចឹមកង្កែប និងដាំទំពាំងផ្អែម បានចំនួន ៧បណ្តុំ ស្មើនឹង ១១ក្រុម មានមនុស្សសរុប ៥២៤នាក់ ដោយ មានអាជីវករចូលទិញដល់កន្លែងតាមតម្លៃទីផ្សារសេរី។

-បានយកចិត្តទុកដាក់ខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបានចូលរួមផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋនៅមូលដ្ឋានតាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ ដោយបានចុះតាមខ្នងផ្ទះដោយបានចែកម៉ាស់ អាល់កុល ស្បៀង និងបានចែកខិតប័ណ្ណអប់រំប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ផងដែរ ។

**៣.បញ្ហាប្រឈម**

-សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំនៅមានកម្រិត ខ្វះធនធានមនុស្ស

-តម្រូវការរបស់ប្រជាពលរដ្ឋមានលក្ខណៈទំនើប ទាន់សម័យ តាមការរីកចម្រើនរបស់ប្រទេសជាតិ ដូចជាផ្លូវកៅស៊ូ ផ្លូវបេតុង ការដាក់ភ្លើងបំភ្លឺតាមផ្លូវសាធារណៈ។

## ៤.ទិសដៅការងាររបស់ក្រុមប្រឹក្សាឃុំ

- ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចូលរួមចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ
- ជំរុញការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព
- បន្តដោះស្រាយរាល់សំណើ សំណូមពររបស់ប្រជាពលរដ្ឋដែលនៅសេសសល់គ្រប់មូលដ្ឋាន
- បន្តអនុវត្តយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ផ្សព្វផ្សាយ និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់ សារាចរណ៍ណែនាំ និងគោល-ការណ៍នានា
- បន្តអនុវត្តកម្មវិធីវិនិយោគឃុំឱ្យ
- បន្តចូលរួមក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបានចូលរួមផ្សព្វផ្សាយអប់រំណែនាំប្រជាពលរដ្ឋនៅមូលដ្ឋានតាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាល
- បន្តធ្វើវេទិកាសាធារណៈនៅតាមភូមិដើម្បីក្តាប់បានបញ្ហា សំណូមពរ និងរកដំណោះស្រាយជូនប្រជាពលរដ្ឋ
- ជំរុញការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាព
- ជំរុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យមានការចូលដាំដំណាំ បន្លែ ចិញ្ចឹមសត្វ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ
- ជួយស្វែងរកទីផ្សារជូនប្រជាពលរដ្ឋ

ជាទីបញ្ចប់ក្នុងនាមក្រុមប្រឹក្សាឃុំពងទឹក ខ្ញុំបាទសូមគោរពជូនពរ ឯកឧត្តម រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល គណៈប្រតិភូខេត្តកែប និងឯកឧត្តម លោកជំទាវ និងបងប្អូនអ្នកសារព័ត៌ដែលមាននៅទីនេះ សូមជួបប្រទះនូវពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរព្រះគុណ និងសូមអរគុណ**!